# ស្ថានទូតអូស្ត្រាលី
# រាជធានីភ្នំពេញ

## សេចក្តីប្រកាសពត៌មាន

### និស្សិតកម្ពុជា៥៤រូបបានទទួលអាហារូបករណ៍ទៅសិក្សានៅប្រទេសអូស្ត្រាលីក្នុងឆ្នាំ ២០១៣

នៅថ្ងៃទី ១១ ធ្នូ ឆ្នាំ២០១២នេះ **លោកជំទាវ ផេននី រីឆាដស៍** ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅកម្ពុជានឹងប្រារព្ធពិធីជប់លៀងជូនដំណើរនិស្សិតកម្ពុជាចំនួន**៥២រូប** ដែលបានប្រលងជាប់អាហារូបករណ៍ទៅសិក្សាថ្នាក់ក្រោយឧត្តមនៅប្រទេសអូស្ត្រាលី។

និស្សិតកម្ពុជាទាំង៥២រូបដែលមានខ្លះមកពីស្ថាប័នរដ្ឋាភិបាល សង្គមស៊ីវិល និង ផ្នែកឯកជននឹងទៅបន្តការសិក្សាថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់និង ថ្នាក់បណ្ឌិត នៅ តាមបណ្តាមហាវិទ្យាល័យដែលមានកិត្យានុភាពនានានៅក្នុងប្រទេសអូស្ត្រាលីនៅឆ្នាំ២០១៣ ដែលពួកគេទទួលបានការឧបត្ថម្ភថវិកាទាំងស្រុងតាមរយៈកម្មវិធីអាហារូបករណ៍របស់រដ្ឋាភិបាលអូស្ត្រាលី។ ពួកគេនឹងទៅសិក្សានៅលើវិស័យចំបងនានាដូចជា សុខាភិបាល កសិកម្ម និង អភិវឌ្ឍន៍ជនបទ ហេដ្ឋារចនាសម្ព័ន្ធ កំណែរទម្រង់ប្រព័ន្ធច្បាប់ និង យុត្តិធម៌ និង ចំនុចជាអន្តរវិស័យមួយចំនួនរួមមាន ការគ្រប់គ្រងជំនួយប្រកបដោយប្រសិទ្ធិភាព សេវាសង្គម គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង សមភាពយ៉េនឌ័រ។

កម្មវិធីអាហារូបករណ៍អូស្ត្រាលី ផ្តល់ឪកាសដល់ប្រជាជនមកពីប្រទេសកំពុងអភិវឌ្ឍន៍នានានៅជុំវិញពិភពលោកអោយទៅសិក្សានៅប្រទេសអូស្ត្រាលី។ អ្នកដែលទទួលបានអាហារូបករណ៍គឺជាអ្នកដែលមានសមិទ្ធិផលការងារខ្ពស់ និង មានសក្តានុពលអាចក្លាយជាអ្នកដឹកនាំ ហើយពួកគេមានបំនងក្នុងការបង្កើននូវចំណេះដឹង ជំនាញ និង ឯកទេសសំរាប់គាំទ្រដល់ការអភិវឌ្ឍន៍រយៈពេលវែងនៅក្នុងប្រទេសរបស់ពួកគេ។

កម្មវិធីអាហារូបករណ៍អូស្ត្រាលី ពង្រឹងបន្ថែមនូវទំនាក់ទំនងជាវិជ្ជមានរវាងរដ្ឋាភិបាល និង ប្រជាជននៃប្រទេសទាំងពីរ។ ហើយទំនាក់ទំនងនេះក៏នឹងជួយ ពង្រឹងដល់បណ្តាញធុរកិច្ច សិក្សាធិការ និងសង្គម ដែលនឹងជំរុញដល់ការអភិវឌ្ឍន៍ទាំងក្នុងស្រុក និងក្នុងតំបន់។

រដ្ឋាភិបាលអូស្ត្រាលី បានតាំងចិត្តជំរុញលើវិស័យឧត្តមសិក្សា និងការអភិវឌ្ឍន៍សមត្ថភាពរបស់ប្រជាជននៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ក្នុងឆ្នាំ២០១២ និស្សិតកម្ពុជាសរុប**៥៥រូប** ត្រូវបានជ្រើសរើសនៅក្នុងកម្មវិធីអាហាររូបករណ៍ដើម្បីទៅសិក្សាថ្នាក់ក្រោយឧត្តម នៅប្រទេស

អូស្ត្រាលី។ ចាប់តាំងពីឆ្នាំ១៩៩៤មក មាននិស្សិតកម្ពុជាច្រើនជាង៥០០នាក់ បានទទួលអាហារូបករណ៍សំរាប់ការអភិវឌ្ឍន៍រយៈពេលវែង ដែលមាន គាំទ្រនិងឧបត្ថម្ភថវិកាទាំងស្រុងដោយរដ្ឋាភិបាលអូស្ត្រាលី។ ក្នុងចំនោមនោះ មាននិស្សិតច្រើនជាង ៣២០នាក់ បានបញ្ចប់ការសិក្សា ដោយជោគជ័យ ហើយត្រលប់មកកម្ពុជាវិញដោយមានជំនាញវិជ្ជាជីវៈខ្ពស់ជាងមុន ក្រៅ ពីនេះនៅមាននិស្សិតខ្លះទៀតកំពុងតែបន្តការសិក្សានៅប្រទេសអូស្ត្រាលី មាន ខ្លះក៏កំពុងទទួលវគ្គហ្វឹកហ្វឺនបន្ថែមនៅក្នុងប្រទេសកម្ពុជា និងខ្លះទៀតត្រៀមចេញដំណើរទៅប្រទេសអូស្ត្រាលីនៅក្នុងខែមករាខាងមុខនេះ។

និស្សិតដែលត្រលប់មកវិញ បានចូលរួមចំនែកយ៉ាងសំខាន់សំរាប់ការអភិវឌ្ឍន៍សង្គមនិងសេដ្ឋកិច្ចនៅកម្ពុជា ហើយ ពួកគេភាគច្រើនក៏កំពុងតែឡើងទៅកាន់តួនាទី មុខតំណែងជាន់ខ្ពស់នៅក្នុង ជួររដ្ឋាភិបាល សង្គមស៊ីវិល និង ផ្នែកជំនួញ។

ស្ថានទូតអូស្ត្រាលីមានមោទនភាព ក្នុងការជប់លៀងជូនដំណើរដល់ក្រុមនិស្សិតកម្ពុជាដ៏មានសក្តានុពលនិងមានសមត្ថភាពប្លែកៗពីគ្នានេះ ហើយសូមជូនពរអោយការធ្វើដំណើររបស់ពួកគេប្រកបដោយជោគជ័យទាំងការសិក្សារ និងការទទួលបាននូវបទពិសោធន៍ផ្ទាល់ខ្លួនល្អៗពីប្រទេសអូស្ត្រាលី។

**ព័ត៌មានលំអិតនៃកម្មវិធី**

*កាលបរិច្ឆេទ៖ ថ្ងៃអង្គារ ១១ ធ្នូ ២០១២ ពីម៉ោង ១៨០០ ដល់ ២០៣០*

*ទីតាំង៖ សណ្ឋាគារ កាំបូឌីយ៉ាណា ភ្នំពេញ*

សំរាប់ព័ត៌មានបន្ថែមនៃកម្មវិធីអាហារូបករណ៍អូស្ត្រាលី www.australiaawards.gov.au

**ទំនាក់ទំនងសារព័ត៌មាន:**

លោក **ដេវ ហ្គ័រដ្យ** (Dave Gordge) លេខាទីមួយ ស្ថានទូតអូស្ត្រាលីភ្នំពេញ

ទូរស័ព្ទ ០២៣ ២១៣ ៤៧០

៧ ធ្នូ ២០១២